# ចក្កវត្តិសូត្រ

សម័យមួយព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងព្រៃជិតមាតុលានគរ ក្នុងដែនមគធៈ ។ ព្រះមានព្រះភាគទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយក្នុងទីនោះថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីកាព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរមានខ្លួនជាទីពឹង មានខ្លួនជាទីពំនាក់ កុំមានរបស់ដទៃជាទីពឹង ពំនាក់ឡើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានខ្លួនជាទីពឹង មានខ្លួនជាទីពំនាក់ មិនមានរបស់ដទៃជា ទីពឹងពំនាក់ មានធម៌ជាទីពឹងមានធម៌ជាទីពំនាក់ មិនមានរបស់ដទៃជាទីពឹងពំនាក់ តើដូចម្តេច។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណានូវកាយក្នុងកាយជាប្រក្រតី មានព្យាយាម ជាគ្រឿងដុតកំដៅនូវកិលេស មានប្រាជ្ញាដឹងសព្វ មានស្មារតីកំចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកបាន ។ ពិចារណានូវវេទនា ក្នុងវេទនាទាំងឡាយជាប្រក្រតី ពិចារណានូវចិត្តក្នុងចិត្តជាប្រក្រតី ពិចារណានូវធម៌ក្នុងធម៌ទាំងឡាយជាប្រក្រតី មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានប្រាជ្ញាដឹងសព្វ មានស្មារតីកំចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកបាន ។

ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះហៅថា ភិក្ខុមានខ្លួនជាទីពឹង មានខ្លួនជាទីពំនាក់មិនមានរបស់ដទៃជាទីពឹងពំនាក់ មានធម៌ជាទីពឹង មានធម៌ជាទីពំនាក់ មិនមានរបស់ដទៃជាទីពឹងពំនាក់ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរប្រព្រឹត្តក្នុងគោចរជាវិស័យ ដែលមានមកអំពីបិតារបស់ខ្លួន ( ព្រះពុទ្ធ) មារ ( ទេវបុត្រមារ និង កិលេសមារ) ក៏មិនបាននូវចន្លោះ មិនបាននូវអារម្មណ៍ឡើយ ។ ម្នាលភិក្ខុទាំងឡាយ បុណ្យនេះរមែងចំរើនឡើង ព្រោះហេតុសមាទាននូវកុសលធម៌ទាំងឡាយយ៉ាងនេះ ។

ម្នាលភិក្ខុទាំងឡាយ កាលពីព្រេងនាយមក មានព្រះរាជា មួយព្រះអង្គ ទ្រង់ព្រះនាមទឡ្ហនេមិ ជាស្តេចចក្កពត្តិ ព្រះអង្គជាធម្មិកធម្មរាជា ជាឥស្សរៈលើផែនដី ដែលមានសមុទ្រ

ទាំងបួនជាទី បំផុត ជាស្តេចឈ្នះសង្គ្រាម ទ្រង់មានជនបទដល់នូវថិរភាព ទ្រង់បរិបូណ៌ដោយរ័តន៍ទាំង ៧ ប្រការ ។ ឯរ័តន៍ទាំង៧ប្រការរបស់ព្រះបាទទល្ហនេមិនោះគឺ ចក្ករ័តន៍ (ចក្រកែវ) ១ ហត្ថិរ័តន៍ (ដំរីកែវ) ១ អស្សរ័តន៍ (សេះកែវ) ១ មណិរ័តន៍ (កែវមណី) ១ ឥត្ថិរ័ត្ន (ស្ត្រីកែវ) ១ គហបតិរ័តន៍ (គហបតីកែវ) ១ បរិនាយករ័តន៍ (នាយពលកែវ) ១ រួមត្រូវជា ៧ ប្រការ ។ ឯព្រះបាទទល្ហនេមិនោះ មានព្រះរាជបុត្រច្រើនជាងពាន់ សុទ្ធសឹងតែក្លៀវក្លា អង់អាចអាចសង្កត់សង្កិននូវសេនារបស់ស្តេចដទៃបាន ។ ព្រះបាទទល្ហនេមិនោះទ្រង់ត្រួតត្រា គ្រប់គ្រងផែនដីដែលមានសាគរជាព្រំប្រទល់ ដោយធម៌ដ៏ស្មើ មិនបាច់ប្រើអាជ្ញា មិនបាច់ប្រើគ្រឿងសាស្ត្រាវុធទេ ។ ម្នាលភិក្ខុទាំងឡាយ លុះកាលកន្លងទៅបានច្រើនឆ្នាំ ច្រើនរយឆ្នាំ ច្រើនពាន់ឆ្នាំ ទើបព្រះបាទទល្ហនេមិ ទ្រង់ត្រាស់នឹងបុរសម្នាក់ថា ម្នាលបុរសដ៏ចំរើន បើអ្នកឃើញចក្ករ័តន៍ជាទិព្វ ឃ្លាតច្យុតចាកទីក្នុងកាលណា អ្នកត្រូវប្រាប់ដល់យើងក្នុងកាលនោះ។ បុរសនោះទទួលស្តាប់ព្រះរាជឱង្ការនៃព្រះបាទនេមិថា ព្រះករុណាថ្លៃវិសេស ។

លុះកាលកន្លងទៅបានច្រើនឆ្នាំ ច្រើនរយឆ្នាំ ច្រើនពាន់ឆ្នាំ បុរសនោះបានឃើញចក្ករ័តន៍ជាទិព្វ ឃ្លាតច្យុតចាកទីក៏ចូលទៅគាល់ព្រះបាទទល្ហនេមិ លុះចូលទៅដល់ហើយក៏ក្រាបបង្គំទូលព្រះបាទទល្ហនេមិថា សូមព្រះរាជតេជះតម្កល់លើត្បូង បពិត្រព្រះសម្មតិទេពសូមទ្រង់ជ្រាបដ្បិតចក្ករ័តន៍ដ៏ជាទិព្វរបស់ព្រះអង្គ ឃ្លាតច្យុតចាកទីហើយ ។ គ្រានោះឯងព្រះបាទទល្ហនេមិទ្រង់ហៅព្រះរាជកុមារជាបុត្រច្បងមកហើយ ទ្រង់ត្រាស់ដូច្នេះថា ម្នាលកុមារ មាសឪពុក ឮថាចក្ករ័តន៍របស់យើង ឃ្លាតច្យុតចាកទីហើយ សេចក្តីនេះពុកធ្លាប់ឮថា បើចក្ករ័តន៍ជា ទិព្វរបស់ស្តេចអង្គណា ឃ្លាតច្យុតចាកទីហើយ តពីនោះមក ស្តេចអង្គនោះមិនរស់នៅបានយូរឡើយឯកាមជារបស់មនុស្ស ឪពុកបានបរិភោគឆ្អែតស្កប់ស្កល់ហើយ សម័យនេះជាសម័យដែលឪពុកគួរស្វែងរកកាមជាទិព្វវិញ ម្នាលកុមារមាសឪពុក ចូរអ្នកគ្រប់គ្រងផែនដីដែលមានសមុទ្រជាព្រំប្រទល់នេះចុះ ឯឪពុកនឹងកោរ សក់ពុកមាត់ ពុកចង្កា ស្លៀកដណ្តប់កាសាវពស្ត្រ

ចេញចាកផ្ទះ ចូលទៅកាន់ផ្នួស ។ លំដាប់នោះឯង ព្រះបាទទល្ហនេមិទ្រង់លួងលោម ព្រះរាជកុមារជាបុត្រច្បងឱ្យគ្រេកអរក្នុងរាជសម្បត្តិដោយប្រពៃហើយ ក៏ទ្រង់ដាក់ ព្រះកេសា និងព្រះមស្សុ ទ្រង់ស្លៀកដណ្ដប់កាសាវព្រស្ត្រ រួចចេញចាករាជាគារដ្ឋាន ចូលទៅកាន់ផ្នួស។ កាលព្រះរាជឥសីទើបនឹងទ្រង់ព្រះផ្នួសបាន ៧ ថ្ងៃ ចក្កវ័តនឹជាទិព្វក៏បាត់ទៅ ។

លំដាប់នោះ មានបុរសម្នាក់ចូលទៅគាល់ព្រះរាជាជាក្សត្រិយ៍ ដែលបានមុទ្ធាភិសេកហើយ លុះចូលទៅដល់ក៏ក្រាបបង្គំទូលព្រះរាជាថា សូមព្រះតេជះតំកល់លើត្បូង បពិត្រព្រះសម្មតិទេព សូមទ្រង់ជ្រាប ដ្បិតចក្កវ័តនឹជាទិព្វបាត់ទៅហើយ។ លំដាប់នោះឯង កាលបើចក្កវ័តនឹបាត់ទៅ ព្រះរាជាក៏តូចព្រះទ័យ និង សោយនូវសេចក្ដីមិនសប្បាយព្រះហឫទ័យ ។ ព្រះមហាក្សត្រិយ៍ អង្គនោះក៏ចូលទៅគាល់ព្រះរាជឥសី លុះចូលទៅដល់ហើយក៏ក្រាបបង្គំទូលព្រះរាជឥសីដូច្នេះថា សូមព្រះតេជះតំកល់លើត្បូង បពិត្រព្រះសម្មតិទេព សូមទ្រង់ជ្រាប ដ្បិតចក្កវ័តនឹជាទិព្វបាត់ទៅហើយ ។ កាលបើព្រះមហាក្សត្រិយ៍ ក្រាបបង្គំទូលយ៉ាងនេះ ព្រះឥសីទ្រង់ត្រាស់ថា ម្នាលបា កាលបើចក្កវ័តនឹជាទិព្វបាត់ទៅ អ្នកកុំមានសេចក្ដីតូចចិត្ត កុំសោយនូវសេចក្ដី មិនសប្បាយចិត្ត ឡើយ ព្រោះចក្កវ័តនឹជាទិព្វនេះ មិនមែនជាមតិក ដែលមានមកអំពីបិតាអ្នកទេ ។ ម្នាលបា ណើ្ហយចុះ អ្នកចូរប្រព្រឹត្តចក្កពត្តិវត្ត ( វត្តរបស់ស្ដេចចក្រពត្តិ) ដ៏ប្រសើរវិញចុះ កាលបើ ចក្កពត្តិវត្តដែលអ្នកប្រព្រឹត្តហើយ ចក្កវ័តនឹ ជាទិព្វមានកាំ ១ ពាន់ ព្រមទាំងខ្នងកង់ ព្រមទាំងដុំ បរិបូណ៌ដោយអាការសព្វគ្រប់នឹងកើតប្រាកដដល់បាដែលកក់កេសាហើយរក្សាឧបោសថ ឋិតនៅ លើប្រាសាទដ៏ប្រសើរ ក្នុងថ្ងៃ ១៥ ជាថ្ងៃឧបោសថនោះ ហេតុនេះ រមែងមានប្រាកដ ។

ព្រះមហាក្សត្រិយ៍ក្រាបបង្គំទូលសួរថា បពិត្រព្រះសម្មតិទេព ចុះចក្កពត្តិវត្តនោះតើដូចម្ដេច? ព្រះរាជឥសីត្រាស់ថា ម្នាលបា បើដូច្នោះ ចូរអ្នកអាស្រ័យនូវធម៌តែម្យ៉ាង ហើយធ្វើសក្ការៈ ចំពោះធម៌ គោរពធម៌ រាប់អានធម៌ បូជាធម៌ កោតក្រែងធម៌ យកធម៌ជាទង់ជ័យ យកធម៌ជាស្ពាន យកធម៌ជាអធិបតី ចាត់ចែងនូវការរក្សា ទប់ទល់ គ្រប់គ្រង ប្រកបដោយធម៌ ចំពោះជនខាងក្នុង គឺបុត្រភរិយា ចំពោះពួកពល ពួកក្សត្រិយ៍ ពួកជនចុះចូល ពួកព្រាហ្មណ៍

គហបតី ពួកអ្នកនិគម អ្នកជនបទ ពួកសមណព្រាហ្មណ៍ និងពួកម្រឹគ បក្សី ម្នាលបា អ្នកកុំធ្វើអកុសលធម៌ក្នុងដែនរបស់អ្នកឡើយ ។

ម្នាលបា បើពួកជនណាក្នុងដែនរបស់អ្នក មិនមានទ្រព្យ អ្នកគប្បីផ្តល់ទ្រព្យដល់ជនទាំងនោះ ម្នាលបា បើពួកសមណព្រាហ្មណ៍ណាក្នុងដែនរបស់អ្នក ជាអ្នកវៀរចាកសេចក្តីស្រវឹង និងសេចក្តីប្រមាទ តាំងនៅក្នុងខន្តីនិងសោរច្ចៈ តែងទូន្មានខ្លួនឯងតែម្នាក់ឯង ធ្វើខ្លួនឯងអោយស្ងប់តែម្នាក់ឯង ធ្វើខ្លួនឯងអោយរលត់ចាករាគាទិក្កិលេសតែងម្នាក់ឯង អ្នកគប្បីចូលទៅរកសមណព្រាហ្មណ៍ទាំងនោះ សព្វៗកាល ហើយគប្បីសាកសួរ គប្បីចោទដណ្តឹងថា បពិត្រលោកដ៏ចំរើន អ្វីជាកុសល បពិត្រលោកដ៏ចំរើន អ្វីជាអកុសល អ្វីជាអំពើប្រកបដោយទោស អ្វីជាអំពើមិនប្រកបដោយទោស អ្វីគួរសេព អ្វីមិនគួរសេព អំពើដូចម្តេចដែលខ្ញុំធ្វើទៅហើយមិនជាប្រយោជន៍ ជាទុក្ខអស់កាលយូរអង្វែង អំពើដូចម្តេច ដែលខ្ញុំធ្វើទៅហើយជាប្រយោជន៍ ជាសុខអស់កាលយូរអង្វែង ។ លុះអ្នកបានស្តាប់ពាក្យសមណព្រាហ្មណ៍ទាំងនោះហើយ គប្បីវៀរនូវអំពើជាអកុសល ម្នាលបា នេះឯងជាចក្កពត្តិវត្តដ៏ប្រសើរនោះ ។

ម្នាលភិក្ខុទាំងឡាយ ព្រះរាជាជាក្សត្រិយ៍ដែលបានមុទ្ធាភិសេកហើយ បានទទួលស្តាប់ពាក្យព្រះរាជឥសីថា ព្រះករុណាថ្លៃវិសេស ហើយក៏ប្រព្រឹត្តចក្កពត្តិវត្ត ដ៏ប្រសើរ។ កាលដែលព្រះរាជានោះ កំពុងប្រព្រឹត្តចក្កពត្តិវត្តដ៏ប្រសើរ កក់ព្រះកេសា សមាទានឧបោសថ ហើយស្តេចទៅខាងលើប្រាសាទដ៏ប្រសើរក្នុងថ្ងៃទី ១៥ ដែលជាថ្ងៃឧបោសថនោះ ចក្ករ័តន៍ជាទិព្វមានកង់ ១ពាន់ ព្រមទាំងខ្នងកង់ព្រមទាំងដុំ បរិបូណ៌ដោយអាការសព្វគ្រប់ក៏កើតប្រាកដឡើង ។ ព្រះរាជាទ្រង់ទតឃើញហើយ ទ្រង់ព្រះរាជតម្រិះថា អាត្មាអញបានឮមកដូច្នេះថា ចក្ករ័តន៍ជាទិព្វមានកង់ ១ពាន់ ព្រមទាំងខ្នងកង់ព្រមទាំងដុំ បរិបូណ៌ដោយអាការសព្វគ្រប់ក៏កើតប្រាកដឡើង ដល់ព្រះរាជាជាក្សត្រិយ៍អង្គណា ដែលបានមុទ្ធាភិសេកហើយ កក់ព្រះកេសា សមាទានឧបោសថ ហើយស្តេចទៅខាងលើប្រាសាទដ៏ប្រសើរក្នុងថ្ងៃទី ១៥ ដែលជាថ្ងៃ

ឧបោសថនោះ ព្រះរាជាអង្គនោះនឹងជាស្តេចចក្រពត្តិ ឱហ្ន៎! អាត្មាអញប្រាកដជាស្តេចចក្រពត្តិហើយតើ ។

គ្រានោះ ព្រះរាជាទ្រង់ក្រោកអំពីអាសនៈ ធ្វើសំពត់ឧត្តរាសង្គៈឆៀងស្មាម្ខាង ទើបយកព្រះហស្តខាងឆ្វេងកាន់កុណ្ឌី យកព្រះហស្តខាងស្តាំប្រស់ព្រំចក្កវ័តន៏ ហើយអធិដ្ឋានថា សូមឱ្យចក្កវ័តន៏ដ៏ចំរើនប្រព្រឹត្តទៅ សូមឱ្យចក្កវ័តន៏ដ៏ចំរើនមានជ័យជំនះចុះ ។ គ្រានោះ ចក្កវ័តន៏នោះក៏អណ្តែតត្រសែតទៅកាន់ទិសខាងកើត ។ ទើបព្រះបាទចក្រពត្តិស្តេចទៅតាមចក្កវ័តន៏នោះ ព្រមដោយចតុរង្គសេនា ។ ម្នាលភិក្ខុទាំងឡាយ បើចក្កវ័តន៏ទៅប្រតិស្ឋានក្នុងប្រទេសណា ព្រះបាទចក្រពត្តិក៏ស្តេចចូលទៅតាំងព្រះរាជនិវេសន៏ ក្នុងប្រទេសនោះ ព្រមដោយចតុរង្គសេនា ។ ចំណែកខាងស្តេចជាសឹកសត្រូវទាំងឡាយណា ដែលនៅក្នុងទិសខាងកើត ស្តេចទាំងនោះក៏ចូលទៅគាល់ព្រះបាទចក្រពត្តិ ហើយក្រាបបង្គំទូលយ៉ាងនេះថា បពិត្រមហារាជ សូមព្រះអង្គស្តេចចូលមកចុះ បពិត្រមហារាជ ព្រះអង្គមានព្រះរាជដំណើរមកស្រួលហើយ បពិត្រមហារាជ ដែនរបស់ខ្ញុំព្រះអង្គជាដែនរបស់ព្រះអង្គហើយ បពិត្រមហារាជ សូមព្រះអង្គទ្រង់ប្រៀនប្រដៅចុះ ។

ព្រះបាទចក្រពត្តិមានព្រះបន្ទូលប្រដៅយ៉ាងនេះថា អ្នកទាំងឡាយមិនត្រូវសំលាប់សត្វ មិនត្រូវលួចទ្រព្យដែលគេមិនបានអោយ មិនត្រូវប្រព្រឹត្តខុសក្នុងកាមទាំងឡាយ មិនត្រូវពោលពាក្យមុសាវ៉ាទ មិនត្រូវផឹកទឹកស្រវឹងឡើយ ចូរបរិភោគតែរបស់ដែលគួរបរិភោគចុះ ។ មួយទៀត ស្តេចជាសឹកសត្រូវណាដែលនៅក្នុងទិសខាងកើត ស្តេចទាំងនោះក៏ទៅជាចុះចូលស្តេចចក្រពត្តិវិញ ។

លំដាប់នោះ ចក្កវ័តន៏នោះក៏ចុះកាន់សមុទ្រក្នុងទិសខាងកើត រួចឆ្លងឡើងចុះទៅកាន់សមុទ្រក្នុងទិសខាងត្បូង រួចឆ្លងឡើងអណ្តែតត្រសែតក្នុងទិសខាងលិច ។ ស្តេចចក្រពត្តិអង្គនោះញ៉ាំងព្រះរាជាជាសត្រូវទាំងឡាយដែលនៅទិសខាងលិចអោយខ្ជួបខ្ជាច ហើយទ្រង់ប្រៀនប្រដៅអោយតាំងនៅក្នុងសីល៥ តាមដំណើរដូចព្រះរាជាដែលនៅទិសខាងកើតដែរ ។ លំដាប់នោះ ចក្កវ័តន៏នោះក៏ចុះកាន់សមុទ្រក្នុងទិសខាងលិច ឡើងអណ្តែតត្រសែតទៅកាន់ទិសខាងជើង ព្រះ

បាទចក្រពត្តិស្ដេចទៅតាមចក្កវ័តន៏នោះ ព្រមដោយចតុរង្គសេនា ហើយព្រះរាជានៅទិសខាងជើងក៏ទ្រង់ខ្ជួបខ្លាចអំណាចព្រះអង្គ ព្រះបាទចក្រពត្តិទ្រង់ប្រៀនប្រដៅព្រះរាជាទាំងឡាយនោះអោយតាំងនៅក្នុងសីល ៥ ដូចព្រះរាជាក្នុងទិសនានាដែរ ។ លំដាប់នោះ ចក្កវ័តន៏នោះក៏បង្ក្រាបដែនដីដែលមានសមុទ្រជាព្រំប្រទល់ ហើយត្រឡប់មកកាន់ព្រះរាជធានីនោះវិញ ឋិតនៅក្នុងរបៀងនៃសាលាវិនិច្ឆ័យទ្បេបទ្វារព្រះរាជវាំងនៃព្រះបាទចក្រពត្តិ នៅនឹងថ្កល់ហាក់ដូចជាបាក់ភ្លៅបំភ្លឺព្រះរាជវាំងរបស់ព្រះបាទចក្រពត្តិអោយភ្លឺព្រោងព្រាត ។

ស្ដេចចក្រពត្តិទី២ ក្ដី ទី៣ ក្ដី ទី៤ ក្ដី ទី៥ ក្ដី ទី៦ ក្ដី ទី៧ ក្ដី ក៏ទ្រង់អនុវត្ត និង ប្រតិបត្តិនូវចក្កពិត្តិវត្តដូចគ្នា ។ លុះកាលកន្លងទៅច្រើនពាន់ឆ្នាំ ព្រះរាជាអង្គបន្ទាប់មកទៀតទ្រង់លះបង់រាជសម្បត្តិអោយរាជបុត្រច្បងរួចហើយ ក៏ទ្រង់ចេញសាងព្រះផ្នួស តាមដំណើរដូចព្រះរាជាអង្គមុនកាលព្រះរាជឥសីទើបនឹងបួសបាន ៧ ថ្ងៃ ចក្កវ័តន៏ជាទិព្វក៏បាត់ទៅ ។

គ្រានោះឯង បុរសម្នាក់បានក្រាបបង្គំទូលព្រះរាជាអង្គថ្មីថា ចក្កវ័តន៏ជាទិព្វបាត់ទៅហើយ កាលបើចក្កវ័តន៏ជាទិព្វបាត់ទៅ ព្រះរាជាក៏ទ្រង់តូចព្រះហឫទ័យ និង សោយនូវសេចក្ដីមិនសប្បាយក្នុងព្រះហឫទ័យ តែមិនចូលទៅសួរវត្តរបស់ស្ដេចចក្រពត្តិដ៏ប្រសើរ នឹងព្រះរាជឥសីឡើយ ។

បានឮថា ព្រះរាជាទ្រង់ប្រៀនប្រដៅអ្នកជនបទតាមព្រះយោបល់របស់ព្រះអង្គ កាលព្រះរាជានោះទ្រង់ប្រៀនប្រដៅអ្នកជនបទតាមយោបល់របស់ព្រះអង្គហើយ លុះចំណេរមកខាងក្រោយ អ្នកជនបទក៏មិនចំរើនស្មើនឹងកាលមុនដូចកាលស្ដេចទាំងឡាយជាន់ដើម ដែលប្រព្រឹត្តវត្តរបស់ស្ដេចចក្រពត្តិដ៏ប្រសើរឡើយ ។ គ្រានោះឯង ពួកអាមាត្យ ពួកបរិស័ទ ពួកហោរានិងមហាមាត្យ ពួកហ្មដីរ ពួកអ្នករក្សាទ្វារ និងពួកជនអ្នកចិញ្ចឹមជីវិតដោយមន្ត ក៏ប្រជុំគ្នាចូលទៅក្រាបបង្គំទូលព្រះរាជាថា បពិត្រព្រះសម្មតិទេព បានឮថា កាលព្រះអង្គទ្រង់ប្រៀនប្រដៅអ្នកជនបទដោយព្រះយោបល់របស់ព្រះអង្គ លុះចំណេរមកខាងក្រោយមក អ្នកជនបទក៏មិនចំរើនស្មើនឹងកាលមុន ដូចកាលស្ដេចទាំងឡាយជាន់ដើម ដែលប្រព្រឹត្តវត្តរបស់ស្ដេចចក្រពត្តិ

ដ៏ប្រសើរឡើយ បពិត្រព្រះសម្មតិទេព ពួកខ្ញុំព្រះអង្គក្តី ពួកជនដទៃក្តី ក៏មាននៅក្នុងដែនរបស់ព្រះអង្គស្រាប់ហើយ យើងខ្ញុំទាំងឡាយសុទ្ធតែចាំស្ទាត់នូវចក្កពត្តិវត្តដ៏ប្រសើរ បពិត្រព្រះសម្មតិទេព ពួកខ្ញុំព្រះអង្គសូមរំលឹក សូមព្រះអង្គទ្រង់សួរនូវចក្កពត្តិវត្តដ៏ប្រសើរនឹងពួកខ្ញុំព្រះអង្គចុះ ពួកខ្ញុំព្រះអង្គ បើព្រះអង្គទ្រង់ត្រាស់សួរនូវចក្កពត្តិវត្តដ៏ប្រសើរហើយ មុខជានឹងព្យាករណ៍បាន ។ លំដាប់នោះឯង ព្រះរាជាទ្រង់ត្រាស់បង្គាប់ ពួកអាមាត្យ ពួកបរិស័ទ ពួកហោរានិងមហាមាត្យ ពួកហ្មង៉ីរ ពួកអ្នករក្សាទ្វារ និងពួកជនអ្នកចិញ្ចឹមជីវិតដោយមន្ត ឱ្យប្រជុំគ្នាហើយទ្រង់សួរនូវចក្កពត្តិវត្តដ៏ប្រសើរ ។ ជនទាំងនោះ កាលព្រះរាជាអង្គនោះទ្រង់សួរនូវចក្កពត្តិវត្តដ៏ប្រសើរហើយ ក៏បានព្យាករណ៍ថ្វាយ ។ លុះព្រះរាជាទ្រង់ព្រះសវនាការពាក្យព្យាករណ៍របស់ជនទាំងនោះហើយ ទើបទ្រង់ចាត់ចែងនូវការរក្សា ទប់ទល់គ្រប់គ្រង ប្រកបដោយធម៌វិញ តែទ្រង់មិនបានព្រះរាជទានព្រះរាជទ្រព្យដល់ពួកអ្នកខ្សត់ទ្រព្យឡើយ ។ កាលដែលទ្រង់មិនបានព្រះរាជទានព្រះរាជទ្រព្យដល់ពួកអ្នកខ្សត់ក្រទ្រព្យ សេចក្តីទាល់ក្រក៏មានច្រើនឡើង ។ កាលបើសេចក្តីទាល់ក្រមានច្រើនឡើងហើយ មានបុរសម្នាក់កាន់យកទ្រព្យរបស់ជនទាំងឡាយដទៃ ដែលគេមិនបានអោយ ដែលហៅថា លួច ។ ពួករាជបុរសចាប់បុរសនោះបាន នាំយកទៅថ្វាយព្រះរាជា ក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព បុរសនេះលួចយកទ្រព្យសម្បត្តិរបស់អ្នកដទៃ ។ កាលបើរាជបុរសក្រាបបង្គំទូលយ៉ាងនេះ ព្រះរាជាក៏ទ្រង់ត្រាស់សួរបុរសនោះដូច្នេះថា នែបុរស អ្នកឯងកាន់យកទ្រព្យរបស់ជនទាំងឡាយដទៃ ដែលគេមិនបានអោយ ដែលហៅថាលួច ពិតមែនឬ? បុរសនោះ ក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព ពិតមែន។ ព្រះរាជាទ្រង់ត្រាស់សួរថា ព្រោះហេតុអ្វីបានជាអ្នកលួចទ្រព្យគេ? បុរសនោះក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេពព្រោះខ្ញុំព្រះអង្គមិនមានរបស់អ្វីនឹងចិញ្ចឹមជីវិត ។ លំដាប់នោះ ព្រះរាជាក៏ទ្រង់ព្រះរាជទានព្រះរាជទ្រព្យដល់បុរសនោះ រួចទ្រង់ត្រាស់បង្គាប់ថា ម្នាលបុរសដ៏ចំរើន អ្នកចូរយកទ្រព្យនេះទៅចិញ្ចឹមជីវិតខ្លួនផង ចិញ្ចឹមមាតាបិតាផង ចិញ្ចឹមបុត្រភរិយាផង ប្រកបការងារផង ចូរតម្កល់ទក្ខិណាទានដែលមានផលខ្ពង់ខ្ពស់ចំពោះសមណព្រាហ្មណ៍ទាំងឡាយ ជាទានអាចនាំសត្វ

អោយកើតក្នុងឋានសួគ៌ មានផលជាសុខ ប្រព្រឹត្តទៅដើម្បីកើតក្នុងឋានសួគ៌ផងចុះ ។ បុរសនោះក៏ទទួលព្រះរាជឱង្ការនៃព្រះរាជាដោយពាក្យថា ព្រះករុណាថ្លៃវិសេស ។ ក្រោយមក មានបុរសម្នាក់ទៀតលួចយកទ្រព្យរបស់អ្នកដទៃ ពួករាជបុរសចាប់បានបុរសនោះក៏នាំយកទៅថ្វាយព្រះរាជា ។ ព្រះរាជាទ្រង់ត្រាស់សួរបុរសនោះសព្វគ្រប់ប្រការដូចដែលបានពោលមកហើយ ហើយបុរសនោះក៏សារភាពតាមត្រង់ ដោយមិនហ៊ានពោលមុសាវាទ ព្រះមហាក្សត្រិយ៍ ក៏ទ្រង់ព្រះរាជទានព្រះរាជទ្រព្យដល់បុរសនោះ ហើយទ្រង់ប្រៀនប្រដៅដូចមុន ។ ពួកមនុស្សបានឮដំណឹងថាព្រះរាជាទ្រង់ព្រះរាជទាន នូវព្រះរាជទ្រព្យដល់ពួកមនុស្ស ដែលកាន់យកទ្រព្យរបស់ជនទាំងឡាយដទៃ ដែលហៅថា លួច ។ លុះមនុស្សទាំងនោះបានឮហើយក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា បើដូច្នេះមានតែពួកយើងនាំគ្នាទៅលួចយកទ្រព្យរបស់ជនទាំងឡាយដទៃកុំខាន ។

លុះគ្រាជាខាងក្រោយមក មានបុរសម្នាក់លួចយកទ្រព្យរបស់អ្នកដទៃ ពួករាជបុរសចាប់បុរសនោះបាន ក៏នាំយកទៅថ្វាយព្រះរាជា ក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេពបុរសនោះឯង លួចយកទ្រព្យរបស់អ្នកដទៃ ដែលគេមិនបានអោយ ។ កាលបើពួករាជបុរសក្រាបបង្គំទូលយ៉ាងនេះហើយ ព្រះរាជាក៏ទ្រង់ត្រាស់សួរបុរសនោះសព្វដំណើរ បុរសនោះក៏ឆ្លើយសារភាពមកតាមត្រង់ថាខ្លួនលួចពិតមែន ។

លំដាប់នោះព្រះរាជាទ្រង់មានសេចក្តីត្រិះរិះដូច្នេះថា បើអាត្មាអញនៅតែអោយទ្រព្យដល់អ្នកដែលលួចយកទ្រព្យរបស់អ្នកដទៃ តែយ៉ាងនេះ មុខជាអទិន្នាទាននឹងរីងរឹតតែចំរើនឡើងបើដូច្នោះគួរតែអាត្មាអញផ្ចាញ់ផ្ចាលបុរសនេះ គួរធ្វើនូវការផ្តាច់ផ្តិលឫសគល់គឺកាត់ក្បាលវាចេញទើបព្រះរាជាទ្រង់ត្រាស់បង្គាប់ពួករាជបុរសថា នៃព្រះស្តែង បើដូច្នោះ ចូរអ្នកទាំងឡាយចងស្លាបសេកបុរសនេះអោយជាប់ដោយខ្សែដ៏មាំ ហើយកោរក្បាលអោយរលីង រួចត្រូវទូងស្គរដែលមានសំលេងឮខ្លាំង នាំបណ្តើរជុំវិញសព្វច្រក សព្វផ្លូវបំបែករួចនាំចេញទៅផ្លូវខាងត្បូង ហើយចូរផ្ចាញ់ផ្ចាលធ្វើនូវការផ្តាច់ផ្តិលឫសគល់ គឺកាត់ក្បាលវាចេញក្នុងទិសខាងត្បូងនៃក្រុងចុះ ។

រាជបុរសទាំងអស់នោះទទួលព្រះរាជឱង្ការព្រះរាជាហើយ ក៏យកបុរសនោះទៅកាត់ក្បាលសំលាប់តាមព្រះរាជបញ្ជា ។

ពួកមនុស្សបានឮដំណឹងថា ពួកជនណាលួចយកទ្រព្យរបស់អ្នកដទៃ ព្រះរាជាទ្រង់អោយគេកាត់ក្បាលពួកជនទាំងនោះ ។ លុះមនុស្សទាំងនោះបានឮហើយក៏គិតយ៉ាងនេះថា បើដូច្នោះមានតែពួកយើងនាំគ្នាធ្វើគ្រឿងសស្ត្រាវុធដ៏មុតភ្លា លុះនាំគ្នាធ្វើរួចហើយ នឹងលួចយកទ្រព្យរបស់ពួកជនណា ហើយពួកយើងនឹងផ្តាញ់ផ្តាលនូវជនទាំងនោះ នឹងធ្វើការផ្តាច់ផ្តិលនូវឫសគល់ គឺកាត់ក្បាលរបស់ជនទាំងនោះចេញ ។ មនុស្សទាំងនោះក៏នាំគ្នាធ្វើគ្រឿងសស្ត្រាវុធដ៏មុតភ្លា លុះធ្វើបានហើយ ក៏ព្យាយាមធ្វើនូវការសំលាប់អ្នកស្រុកខ្លះ អ្នកនិគមខ្លះ អ្នកនគរខ្លះ ធ្វើនូវការប្លន់អ្នកដើរផ្លូវខ្លះ ។ មនុស្សទាំងនោះតែងតែកាន់យកទ្រព្យរបស់ពួកជនណា ដែលគេមិនបានអោយ ដែលហៅថាលួច ហើយផ្តាញ់ផ្តាលពួកជនទាំងនោះ ដោយធ្វើនូវការផ្តាច់ផ្តិលឫសគល់ គឺកាត់ក្បាលជនទាំងនោះ ។

ម្នាលភិក្ខុទាំងឡាយ កាលបើព្រះមហាក្សត្រិយ៍មិនទ្រង់ព្រះរាជទានព្រះរាជទ្រព្យដល់ពួកអ្នកខ្សត់ទ្រព្យដូច្នេះ សេចក្តីទាល់ក្រក៏មានច្រើនឡើង កាលបើសេចក្តីទាល់ក្រមានច្រើនឡើងហើយ អទិន្នាទានក៏មានច្រើនឡើង កាលបើអទិន្នាទានមានច្រើនឡើងហើយ បាណាតិបាតក៏មានច្រើនឡើង កាលបើបាណាតិបាត មានច្រើនឡើងហើយ មុសាវាទក៏មានច្រើនឡើង កាលបើមុសាវាទមានច្រើនឡើងហើយ ទាំងអាយុទាំងពណ៌សម្បុររបស់សត្វទាំងនោះក៏ថយចុះ កាលបើសត្វទាំងនោះថយអាយុថយពណ៌សម្បុរចុះហើយ កូនទាំងឡាយរបស់មនុស្សដែលមានអាយុ ៨ ម៉ឺនឆ្នាំ ក៏ថយមកមានអាយុត្រឹម ៤ ម៉ឺនឆ្នាំវិញ ។ បណ្តាពួកមនុស្សដែលមានអាយុត្រឹម ៤ម៉ឺនឆ្នាំនោះ មានបុរសម្នាក់លួចយកទ្រព្យរបស់អ្នកដទៃ ពួករាជបុរសក៏ចាប់បុរសនោះ នាំយកទៅថ្វាយព្រះរាជា ហើយក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព បុរសនេះលួចយកទ្រព្យរបស់អ្នកដទៃ ។ ព្រះរាជាទ្រង់ត្រាស់សួរបុរសនោះថា នែបុរសដ៏ចំរើន អ្នកឯងលួចយកទ្រព្យរបស់អ្នក

ដទៃ ពិតមែនឬ? បុរសនោះក៏ពោលសម្បជានមុសាវាទ (=ពាក្យកុហកដែលពោលបិទបាំងទោសខ្លួន) ថា បពិត្រព្រះសម្មតិទេព មិនមែនទេ ។

ម្នាលភិក្ខុទាំងឡាយ កាលបើព្រះមហាក្សត្រិយ៍ មិនទ្រង់ព្រះរាជទានព្រះរាជទ្រព្យដល់ពួកអ្នកខ្សត់ទ្រព្យដូច្នេះហើយ សេចក្តីទាល់ក្រក៏មានច្រើនឡើង កាលបើសេចក្តីទាល់ក្រមានច្រើនឡើងហើយ អទិន្នាទានក៏មានច្រើនឡើង កាលបើអទិន្នាទានមានច្រើនឡើងហើយ គ្រឿងសស្ត្រាវុធក៏មានច្រើនឡើង កាលបើគ្រឿងសស្ត្រាវុធមានច្រើនឡើងហើយ បាណាតិបាតក៏មានច្រើនឡើង កាលបើបាណាតិបាតមានច្រើនឡើងហើយ មុសាវាទក៏មានច្រើនឡើង កាលបើមុសាវាទមានច្រើនឡើងហើយ ទាំងអាយុទាំងពណ៌សម្បុរ របស់សត្វទាំងនោះក៏ថយចុះ កាលសត្វទាំងនោះថយទាំងអាយុថយទាំងពណ៌សម្បុរចុះហើយ កូនទាំងឡាយរបស់មនុស្សដែលមានអាយុ៤ម៉ឺនឆ្នាំ ក៏ថយមកមានអាយុត្រឹម២ម៉ឺនឆ្នាំវិញ ។ បណ្តាពួកមនុស្សដែលមានអាយុត្រឹម ២ ម៉ឺនឆ្នាំនោះ មានបុរសម្នាក់លួចយកទ្រព្យរបស់ជនទាំងឡាយដទៃ បុរសម្នាក់នាំយកសេចក្តីនោះទៅក្រាបទូលព្រះញ៉ូវព្រះរាជាថា បពិត្រព្រះសម្មតិទេព បុរសឈ្មោះនេះលួចយកទ្រព្យសម្បត្តិអ្នកដទៃ ។

កាលបើព្រះរាជាមិនទ្រង់ប្រទានព្រះរាជទ្រព្យដល់អ្នកខ្សត់ទ្រព្យដូច្នេះហើយ សេចក្តីទាល់ក្រក៏កើតមានឡើង កាលបើសេចក្តីទាល់ក្រកើតមានឡើងហើយ ។ល។ បិសុណាវាចាក៏មានច្រើនឡើង កាលបើបិសុណាវាចាមានច្រើនឡើងហើយ ទាំងអាយុទាំងពណ៌សម្បុររបស់សត្វទាំងនោះក៏ថយចុះ កាលបើសត្វទាំងនោះថយទាំងអាយុថយទាំងពណ៌សម្បុរចុះហើយ កូនទាំងឡាយរបស់មនុស្សដែលមានអាយុ២ម៉ឺនឆ្នាំក៏ថយចុះមកត្រឹមអាយុ ១ម៉ឺនឆ្នាំវិញ បណ្តាពួកមនុស្សដែលមានអាយុ ១ម៉ឺនឆ្នាំនោះ សត្វពួកខ្លះមានពណ៌សម្បុរល្អ សត្វពួកខ្លះមានពណ៌សម្បុរអាក្រក់ បណ្តាសត្វទាំងពីរពួកនោះ សត្វណាដែលមានពណ៌សម្បុរអាក្រក់ ក៏ស្រលាញ់ពួកសត្វដែលមានពណ៌សម្បុរល្អ ហើយក៏ប្រព្រឹត្តមិច្ឆាចារនឹងភរិយារបស់ពួកជនដទៃ ។

ម្នាលភិក្ខុទាំងឡាយ កាលបើព្រះមហាក្សត្រិយ៍ មិនទ្រង់ព្រះរាជទានព្រះរាជទ្រព្យ ដល់ពួកអ្នកខ្សត់ទ្រព្យដូច្នេះហើយ សេចក្តីទាល់ក្រក៏មានច្រើនឡើង កាលបើសេចក្តីទាល់ក្រមានច្រើនឡើងហើយ អទិន្នាទានក៏មានច្រើនឡើង ។ល។ កាមេសុមិច្ឆាចារ ក៏មានច្រើនឡើង កាលបើកាមេសុមិច្ឆាចារមានច្រើនឡើងហើយ ទាំងអាយុទាំងពណ៌សម្បុររបស់សត្វទាំងនោះក៏ថយចុះ កាលសត្វទាំងនោះថយទាំងអាយុទាំងពណ៌សម្បុរចុះហើយ កូនទាំងឡាយរបស់មនុស្ស ដែលមានអាយុ១ ម៉ឺនឆ្នាំ ក៏ថយមកមានអាយុត្រឹម៥ ពាន់ឆ្នាំវិញ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងពីរប្រការគឺ ផរុសវាចា ១ សម្ផប្បលាបៈ ១ ក៏មានច្រើនឡើង ក្នុងពួកមនុស្ស ដែលមានអាយុត្រឹម ៥ ពាន់ឆ្នាំ កាលបើធម៌ទាំងពីរប្រការមានច្រើនឡើងហើយ ទាំងអាយុទាំងពណ៌សម្បុររបស់សត្វទាំងនោះក៏ថយចុះ កាលសត្វទាំងនោះថយទាំងអាយុទាំងពណ៌សម្បុរចុះហើយ កូនទាំងឡាយរបស់ពួកមនុស្សដែលមានអាយុ ៥ ពាន់ឆ្នាំ ពួកខ្លះក៏ថយមកត្រឹម ២ ពាន់ ៥ រយឆ្នាំវិញ ពួកខ្លះក៏ថយមកមានអាយុត្រឹម ២ ពាន់ឆ្នាំវិញ ។ ម្នាលភិក្ខុទាំងឡាយ អភិជ្ឈានិងព្យាបាទក៏មានច្រើនឡើង ក្នុងពួកមនុស្សដែលមានអាយុត្រឹម ២ ពាន់ ៥ រយឆ្នាំ កាលអភិជ្ឈានិងព្យាបាទ មានច្រើនឡើងហើយ ទាំងអាយុទាំងពណ៌សម្បុររបស់សត្វទាំងនោះក៏ថយចុះ កាលសត្វទាំងនោះថយទាំងអាយុទាំងពណ៌សម្បុរចុះហើយ កូនទាំងឡាយរបស់មនុស្សដែលមានអាយុ ២ ពាន់ ៥ រយឆ្នាំក៏ថយមកមានអាយុត្រឹម ១ ពាន់ឆ្នាំវិញ ។ ម្នាលភិក្ខុទាំងឡាយ មិច្ឆាទិដ្ឋិក៏មានច្រើនក្នុងពួកមនុស្សដែលមានអាយុត្រឹម ១ ពាន់ឆ្នាំ កាលបើមិច្ឆាទិដ្ឋិមានច្រើនឡើងហើយ ទាំងអាយុទាំងពណ៌សម្បុររបស់សត្វទាំងនោះក៏ថយចុះ កាលសត្វទាំងនោះថយទាំងអាយុទាំងពណ៌សម្បុរចុះហើយ កូនទាំងឡាយរបស់មនុស្សដែលមានអាយុ ១ ពាន់ឆ្នាំ ក៏ថយមកមានអាយុត្រឹម ៥ រយឆ្នាំវិញ ។ ធម៌ទាំងឡាយបីប្រការគឺ អធម្មរាគៈ ១ វិសមលោភៈ ១ មិច្ឆាធម្មៈ ១ ក៏មានច្រើនក្នុងពួកមនុស្សដែលមានអាយុត្រឹម ៥ រយឆ្នាំ កាលបើធម៌ បីប្រការមានច្រើនឡើងហើយ ទាំងអាយុទាំងពណ៌សម្បុររបស់សត្វទាំងនោះក៏ថយចុះ កាលសត្វទាំងនោះថយទាំងអាយុទាំងពណ៌សម្បុរចុះហើយ កូនទាំងឡាយរបស់ មនុស្សដែលមានអាយុ ៥ រយឆ្នាំ ពួកខ្លះក៏ថយអាយុមក

ត្រឹម ២ រយ ៥០ ឆ្នាំវិញ ពួកខ្លះក៏ថយមកមានអាយុត្រឹម ២ រយឆ្នាំវិញ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយនេះគឺ ការមិនគោរពមាតា មិនគោរពបិតា មិនគោរពសមណៈ មិនគោរពព្រាហ្មណ៍ មិនប្រព្រឹត្តកោតក្រែងដល់បុគ្គលជាធំក្នុងត្រកូល ក៏មានច្រើនឡើងក្នុងពួកមនុស្សដែលមានអាយុត្រឹម ២ រយ ៥០ ឆ្នាំ ។

ម្នាលភិក្ខុទាំងឡាយ កាលបើព្រះមហាក្សត្រមិនទ្រង់ព្រះរាជទានព្រះរាជទ្រព្យដល់ពួកអ្នកខ្សត់ទ្រព្យដូច្នេះហើយ សេចក្តីទាល់ក្រក៏មានច្រើនឡើង កាលបើសេចក្តីទាល់ក្រមានច្រើនឡើងហើយ អទិន្នាទានក៏មានច្រើនឡើង កាលអទិន្នាទានមានច្រើនឡើងហើយ គ្រឿងសស្ត្រាវុធក៏មានច្រើនឡើង កាលគ្រឿងសស្ត្រាវុធមានច្រើនឡើងហើយ បាណាតិបាតក៏មានច្រើនឡើង កាលបាណាតិបាតមានច្រើនឡើងហើយ មុសាវាទក៏មានច្រើនឡើង កាលមុសាវាទមានច្រើនឡើងហើយ បិសុណាវាចាក៏មានច្រើនឡើង កាលបិសុណាវាចាមានច្រើនឡើងហើយ កាមេសុមិច្ឆាចារក៏មានច្រើនឡើង ហើយធម៌ពីរប្រការគឺ ផរុសវាចា ១ សម្ផប្បលាបៈ ១ ក៏មានច្រើនឡើង កាលធម៌ពីរប្រការមានច្រើនឡើងហើយ អភិជ្ឈានិងព្យាបាទក៏មានច្រើនឡើង កាលអភិជ្ឈានិងព្យាបាទមានច្រើនឡើងហើយ មិច្ឆាទិដ្ឋិក៏មានច្រើនឡើង កាលមិច្ឆាទិដ្ឋិមានច្រើនឡើងហើយ ធម៌បីប្រការ គឺ អធម្មរាគៈ ១ វិសមលោភៈ ១ មិច្ឆាធម្មៈ ១ ក៏មានច្រើនឡើង កាលធម៌បីប្រការមានច្រើនឡើងហើយ ធម៌ទាំងឡាយនេះគឺ ការមិនគោរពមាតា មិនគោរពបិតា មិនគោរពសមណៈ មិនគោរពព្រាហ្មណ៍ មិនប្រព្រឹត្តកោតក្រែងបុគ្គលជាធំក្នុងត្រកូលក៏មានច្រើនឡើង កាលធម៌ទាំងនេះមានច្រើនឡើងហើយទាំងអាយុទាំងពណ៌សម្បុររបស់សត្វទាំងនោះក៏ថយចុះ កាលសត្វទាំងនោះថយទាំងអាយុទាំងពណ៌សម្បុរចុះហើយ កូនទាំងឡាយរបស់មនុស្សដែលមានអាយុ ២ រយ ៥០ ឆ្នាំ ក៏ថយមកមានអាយុត្រឹម ១ រយឆ្នាំវិញ ។

ម្នាលភិក្ខុទាំងឡាយ តទៅខាងមុខ នឹងមានសម័យដែលកូនរបស់មនុស្សទាំងនេះ មានអាយុ ១០ ឆ្នាំ កាលបើមនុស្សមានអាយុ ១០ ឆ្នាំ ពួកនាងកុមារិកាអាយុ ៥ ឆ្នាំ នឹងល្មមអោយមានប្តី ម្នាលភិក្ខុទាំងឡាយ កាលបើមនុស្សមានអាយុ ១០ ឆ្នាំ រសដ៏ប្រសើរទាំងនេះគឺ ទឹកដោះ

ថ្លា ទឹកដោះខាប់ ប្រេង ទឹកឃ្មុំ ទឹកអំពៅ អំបិល នឹងបាត់ទៅ ។ កាលបើពួកមនុស្សមានអាយុ ១០ ឆ្នាំ ស្មៅគែ-លលក នឹងជាភោជនដ៏ប្រសើរ ម្នាលភិក្ខុទាំងឡាយ ក្នុងកាលឥឡូវនេះ បាយស្រូវសាលីលាយដោយសាច់ ជាភោជនដ៏ប្រសើរដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ កាលបើពួកមនុស្សមានអាយុ១០ឆ្នាំ ស្មៅគែ-លលកនឹងជាភោជនដ៏ប្រសើរយ៉ាងនេះឯង ។

កាលបើពួកមនុស្សមានអាយុ ១០ ឆ្នាំ កុសលកម្មបថទាំង ១០ នឹងសាបសូន្យទៅគ្រប់អន្លើ អកុសលកម្មបថទាំង ១០ នឹងចំរើនច្រើនឡើង ។ កាលបើពួកមនុស្សមានអាយុ ១០ ឆ្នាំ សូម្បីពាក្យថា កុសលក៏មិនមាន បើដល់ម្ល៉ោះទៅហើយ មនុស្សអ្នកធ្វើកុសលតើនឹងមានមកពីណា ? កាលបើមនុស្សមានអាយុ ១០ ឆ្នាំ ជនទាំងឡាយណាជាអ្នកមិនគោរពមាតា មិនគោរពបិតា មិនគោរពសមណៈ មិនគោរពព្រាហ្មណ៍ មិនប្រព្រឹត្តកោតក្រែងបុគ្គលជាច្បងក្នុងត្រកូល ជនទាំងនោះនឹងជាអ្នកគួរគេបូជាផង នឹងជាអ្នកគួរគេសរសើរផង ។ មនុស្សក្នុងកាលឥឡូវនេះ ដែលជាអ្នកគោរពមាតា គោរពបិតា គោរពសមណៈ គោរពព្រាហ្មណ៍ ប្រព្រឹត្តកោតក្រែងបុគ្គលជាច្បងក្នុងត្រកូល មនុស្សទាំងនោះទើបជាអ្នកបូជាផង គួរគេសរសើរផង ដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ កាលដែលពួកមនុស្សមានអាយុ ១០ ឆ្នាំ ជនណាមិនគោរពមាតា មិនគោរពបិតា មិនគោរពសមណៈ មិនគោរពព្រាហ្មណ៍ មិនប្រព្រឹត្តកោតក្រែងបុគ្គលជាច្បងក្នុងត្រកូល ជនទាំងនោះទើបជាអ្នកគួរគេបូជាផង គួរគេសរសើរផង ដូច្នោះឯង ។ កាលដែលមនុស្សមានអាយុ ១០ ឆ្នាំ នឹងមិនមានសេចក្តីគោរពកោតក្រែងថា អ្នកនេះជាមាតា ជាម្តាយមីងខាងមាតា ជាបិតា ជាម្តាយមីងខាងបិតា ជាម្តាយធំខាងមាតា ជាភរិយារបស់អាចារ្យ ឬជាប្រពន្ធរបស់គ្រូនៃខ្លួន ដូច្នេះឡើយ សត្វលោកនឹងច្រឡូកច្រឡំគ្នាដូចជា ពពែ មាន់ ជ្រូក ឆ្កែ ចចក ដូច្នោះឯង ។ កាលដែលមនុស្សមានអាយុ ១០ ឆ្នាំ គំនុំដ៏ក្លៀវក្លា ព្យាបាទដ៏ក្លៀវក្លា ចិត្តប្រទូស្តដ៏ក្លៀវក្លា ចិត្តប្រាថ្នានឹងសម្លាប់ដ៏ក្លៀវក្លា នឹងកើតប្រាកដដល់គ្នានិងគ្នា គឺ មាតានិងបុត្រ បុត្រនិងមាតា បិតានិងបុត្រ បុត្រនិងបិតា បងប្អូនប្រុសនិងបងប្អូនស្រី ។ ចិត្តប្រាថ្នានឹងសំលាប់ដ៏ក្លៀវក្លារបស់ព្រានម្រឹគកើតប្រាកដ ព្រោះឃើញម្រឹគ មានឧបមេយ្យដូចម្តេចមិញ កាលដែលមនុស្សមាន

អាយុ ១០ ឆ្នាំ គំនុំ ព្យាបាទ ចិត្តប្រទូស្ត ចិត្តប្រាថ្នានឹងសំលាប់ដ៏ក្លៀវក្លារបស់សត្វទាំងនោះ នឹងកើតប្រាកដដល់គ្នានឹងគ្នា មានឧបមេយ្យដូច្នោះឯង ។ កាលដែលមនុស្សមានអាយុ ១០ ឆ្នាំ សត្ថន្តរកប្ប (លោកវិនាសទៅដោយគ្រឿងសស្ត្រាវុធ) នឹងកើតមានឡើងអស់ ៧ ថ្ងៃ មនុស្ស ទាំងនោះនឹងសំគាល់គ្នាថា ដូចជាម្រឹគ គ្រឿងសស្ត្រាវុធដ៏មុតក្លានឹងជាប់នៅតែក្នុងដៃនៃមនុស្ស ទាំងនោះ មនុស្សទាំងនោះសំគាល់ថា នេះជាម្រឹគហើយក៏ផ្តាច់ផ្តិលជីវិតគ្នានិងគ្នាដោយគ្រឿង សស្ត្រាវុធដ៏មុតក្លា ។ លំដាប់នោះឯង បណ្តាសត្វទាំងនោះ សត្វពួកខ្លះនឹងគិតគ្នាយ៉ាងនេះថា ពួក យើងកុំសំលាប់បុរសណាមួយឡើយ ទាំងបុរសណាមួយក៏កុំសំលាប់ពួកយើងឡើយ បើដូច្នោះ ពួកយើងគួរចូលទៅរកស្មៅស្បាត ព្រៃស្បាត ឈើស្បាត ស្ទឹងដែលទៅមកបានដោយលំបាក ឬភ្នំ ដែលមិនរាបស្មើ ហើយយកមើមនឹងផ្លែឈើក្នុងព្រៃជាអាហារចិញ្ចឹមជីវិត ។
សត្វទាំងនោះនឹងចូលទៅរកស្មៅស្បាត ព្រៃស្បាត ឈើស្បាត ស្ទឹងដែលទៅមកបានដោយលំបាក ឬភ្នំដែលមិនរាបស្មើ ហើយយកមើមនឹងផ្លែឈើក្នុងព្រៃជាអាហារចិញ្ចឹមជីវិតអស់ ៧ ថ្ងៃ ។ លុះថ្ងៃ ៧ នោះកន្លងទៅ ទើបសត្វអម្បាលនោះចេញមក អំពីស្មៅស្បាត អំពីព្រៃស្បាត អំពីឈើ ស្បាត អំពីស្ទឹងដែលទៅមកបានដោយលំបាក អំពីភ្នំដែលមិនរាបស្មើ ហើយឱបគ្នាទៅវិញទៅ មក រួចហើយនិយាយរាក់ទាក់លួងលោមគ្នាក្នុងរោងទាំងឡាយដោយពាក្យថា ម្នាលអ្នកដ៏ចំរើន អ្នករស់នៅដូចពួកសត្វ ដែលយើងបានឃើញហើយ ។ លំដាប់នោះឯងសត្វទាំងអម្បាលនោះ នឹងមានសេចក្តីត្រិះរិះយ៉ាងនេះថា ពួកយើងនេះឯងបានជាដល់នូវការអស់ទៅនៃញាតិជាច្រើន ដូច្នេះ ព្រោះហេតុតែកាន់ធមិជាអកុសលទាំងឡាយ បើដូច្នោះមានតែពួកយើងធ្វើកុសលវិញ តើគួរធ្វើកុសលដូចម្តេច ណ្ហើយចុះ ពួកយើងគួរវៀរចាកបាណាតិបាត ប្រព្រឹត្តសមាទាននូវកុសល ធមិនេះចុះ ។ ទើបសត្វទាំងនោះនាំគ្នាវៀរចាកបាណាតិបាត ប្រព្រឹត្តសមាទាននូវកុសលធមិនេះ សត្វទាំងនោះក៏ចំរើនអាយុ ចំរើនពណ៌សម្បុរឡើង ព្រោះហេតុដែលបានសមាទាននូវកុសលធមិ ទាំងឡាយ កាលសត្វទាំងនោះបានចំរើនអាយុចំរើនពណ៌សម្បុរហើយ កូនទាំងឡាយរបស់ពួក មនុស្សដែលមានអាយុ ១០ ឆ្នាំ ក៏ត្រឡប់ជាមានអាយុ ២០ ឆ្នាំឡើងវិញ ។ លំដាប់នោះឯង

សត្វទាំងអម្បាលនោះនឹងមានសេចក្តីត្រិះរិះយ៉ាងនេះថា ពួកយើងបានចំរើនអាយុ បានចំរើនពណ៌សម្បុរឡើងវិញ ព្រោះហេតុតែបានសមាទាននូវកុសលធម៌ទាំងឡាយ បើដូច្នោះ ពួកយើងគួរធ្វើកុសលអោយច្រើនក្រៃលែងជាងនេះទៅទៀត តើគួរធ្វើកុសលអ្វី ណ្ហើយចុះ ពួកយើងគួរវៀរចាកអទិន្នាទាន គួរវៀរចាកកាមេសុមិច្ឆាចារ គួរវៀរចាកបិសុណាវាចា គួរវៀរចាកផរុសវាចា គួរវៀរចាកសម្ផប្បលាបៈ គួរលះបង់អភិជ្ឈា គួរលះបង់ព្យាបាទ គួរលះបង់មិច្ឆាទិដ្ឋិចេញ គួរលះបង់ធម៌បីប្រការគឺ អធម្មរាគៈ ១ វិសមលោភៈ ១ មិច្ឆាធម្មៈ ១ ចេញ បើដូច្នោះ ពួកយើងជាអ្នកគោរពមាតាបិតា គោរពសមណៈ គោរពព្រាហ្មណ៍ និងជាអ្នកប្រព្រឹត្តកោតក្រែងបុគ្គលជាច្បងក្នុងត្រកូល ពួកយើងគួរនាំគ្នាប្រព្រឹត្តសមាទាននូវកុសលធម៌ទាំងនេះចុះ ។ សត្វទាំងនោះក៏ជាអ្នកគោរពមាតា គោរពបិតា គោរពសមណៈ គោរពព្រាហ្មណ៍ និងជាអ្នកប្រព្រឹត្តកោតក្រែងត្រកូលរៀមច្បង ប្រព្រឹត្តសមាទាននូវកុសលនេះក៏បានចំរើនអាយុ ចម្រើនពណ៌សម្បុរឡើងវិញ ព្រោះហេតុដែលបានសមាទាននូវកុសលធម៌ទាំងនោះ កាលសត្វអម្បាលនោះ ចម្រើនអាយុចំរើនពណ៌សម្បុរឡើងហើយ កូនទាំងឡាយរបស់ពួកមនុស្សដែលមានអាយុ២០ ឆ្នាំ ក៏មានអាយុ ៤០ ឆ្នាំឡើងវិញ ។ កូនទាំងឡាយរបស់ពួកមនុស្សដែលមានអាយុ៤០ឆ្នាំ ក៏មានអាយុ៨០ឆ្នាំឡើងវិញ ។ កូនទាំងឡាយរបស់មនុស្សដែលមានអាយុ៨០ឆ្នាំ ក៏មានអាយុ១៦០ឆ្នាំឡើងវិញ ។ កូនទាំងឡាយរបស់មនុស្សដែលមានអាយុ ១៦០ ឆ្នាំ ក៏មានអាយុ ៣២០ ឆ្នាំឡើងវិញ ។ កូនទាំងឡាយរបស់ពួកមនុស្សដែលមានអាយុ ៣២០ ឆ្នាំ ក៏មានអាយុ ៦៤០ ឆ្នាំឡើងវិញ ។ កូនទាំងឡាយរបស់ពួកមនុស្សដែលមានអាយុ ៦៤០ ឆ្នាំ ក៏មានអាយុពីរពាន់ ឆ្នាំឡើងវិញ ។ កូនទាំងឡាយរបស់ពួកមនុស្សដែលមានអាយុ ពីរពាន់ឆ្នាំក៏មានអាយុ បួនពាន់ឆ្នាំឡើងវិញ ។ កូនទាំងឡាយរបស់ពួកមនុស្សដែលមានអាយុ បួនពាន់ឆ្នាំ ក៏មានអាយុប្រាំបីពាន់ ឆ្នាំឡើងវិញ ។ កូនទាំងឡាយរបស់ពួកមនុស្សដែលមានអាយុប្រាំបីពាន់ឆ្នាំ ក៏មានអាយុពីរម៉ឺនឆ្នាំឡើងវិញ ។ កូនទាំងឡាយរបស់ពួកមនុស្សដែលមានអាយុ ពីរម៉ឺនឆ្នាំ ក៏មានអាយុបួនម៉ឺនឆ្នាំឡើងវិញ ។ កូនទាំងឡាយរបស់ពួកមនុស្សដែលមានអាយុ បួនម៉ឺនឆ្នាំ ក៏មានអាយុប្រាំបីឆ្នាំឡើងវិញ ។

ម្នាលភិក្ខុទាំងឡាយ កាលបើពួកមនុស្សមានអាយុប្រាបីម៉ឺនឆ្នាំ ពួកនាងកុមារិកាមានអាយុ៥០០ ឆ្នាំទើបល្មមអោយមានប្តី ។ កាលបើពួកមនុស្សមានអាយុប្រាំបីម៉ឺនឆ្នាំ នឹងមានអាពាធតែបីយ៉ាងគឺ ចំណង់ក្នុងអាហារ១ បរិភោគអាហារមិនបាន១ សេចក្តីគ្រាំគ្រារាងកាយ១ ។ កាលដែលពួកមនុស្សមានអាយុ៨ម៉ឺនឆ្នាំ ជម្ពូទ្វីបនេះនឹងជាទ្វីបស្តុកស្តម្ភធំទូលាយ មានស្រុក និគម រាជធានីត១គ្នាមួយរយៈមាន់ហើរធ្លាក់ ។ កាលបើមនុស្សមានអាយុ ៨ម៉ឺនឆ្នាំជម្ពូទ្វីបនេះនឹងពេញដោយពួកមនុស្សរកចន្លោះគ្មានដូចអវិចីនរក ពុំនោះសោតដូចព្រៃបបុស ឬព្រៃរាំងភ្នំ ។ ម្នាលភិក្ខុទាំងឡាយ កាលពួកមនុស្សមានអាយុ៨ ម៉ឺនឆ្នាំក្រុងពារាណសីនេះនឹងប្រែឈ្មោះជាកេតុមតីរាជធានីវិញ ជារាជធានីស្តុកស្តម្ភធំទូលាយ មានជនក៏ច្រើន មានមនុស្សកុះករ និងមានភិក្ខាហារដ៏សំបូរ ។ កាលបើពួកមនុស្សមានអាយុ៨ម៉ឺនឆ្នាំ ក្នុងជម្ពូទ្វីបនេះនឹងមាននគរ៨ម៉ឺន ៤ពាន់ មានកេតុមតីរាជធានីឯងជាប្រធាន ។ ម្នាលភិក្ខុទាំងឡាយ កាលដែលមនុស្សមានអាយុ៨ម៉ឺនឆ្នាំ នឹងមានព្រះរាជា ១ព្រះអង្គព្រះនាមសង្ខៈទ្រង់កើតឡើងក្នុងកេតុមតីរាជធានី ជាស្តេចចក្រពត្តិ ទ្រង់ជាធម្មិកធម្មរាជ ជាឥស្សរៈលើផែនដី មានសមុទ្រទាំងបួនជាទីបំផុត ជាស្តេចឈ្នះសង្គ្រាម ទ្រង់មានជនបទដល់នូវថិរភាព ទ្រង់បរិបូរណ៍ដោយរ័ត្ន៧ប្រការ ។ រីឯរ័តន៍ទាំង៧ប្រការរបស់ព្រះបាទសង្ខៈនោះគឺ ចក្ករ័តន៍១ ហត្ថីរ័តន៍១ អស្សរ័តន៍១ មណីរ័តន៍១ ឥត្ថីរ័តន៍១ គហបតីរ័តន៍១ បរិនាយករ័តន៍១ ជាគម្រប់៧ ។ ឯព្រះបាទសង្ខៈនោះនឹងមានព្រះរាជបុត្រច្រើនជាងពាន់ សុទ្ធសឹងក្លៀវក្លាអង់អាច សង្កត់សង្កិននូវសេនារបស់ស្តេចដទៃបាន ។ ព្រះបាទសង្ខៈនោះទ្រង់ត្រួតត្រាគ្រប់គ្រងនូវផែនដីដែលមានសាគរជាទីបំផុត ដោយធមិ មិនបាច់ប្រើអាជ្ញា មិនបាច់ប្រើគ្រឿងសស្ត្រាវុធទេ ។ ម្នាលភិក្ខុទាំងឡាយ កាលបើពួកមនុស្សមានអាយុ៨ម៉ឺនឆ្នាំ ព្រះមានព្រះភាគទ្រង់ព្រះនាមមេត្តេយ្យៈ នឹងកើតឡើងក្នុងលោក ទ្រង់ឆ្ងាយចាកកិលេស ទ្រង់ត្រាស់ដឹងនូវញេយ្យធមិទាំងពួងដោយប្រពៃចំពោះព្រះអង្គ ទ្រង់បរិបូរណ៍ដោយវិជ្ជានិងចរណៈ ទ្រង់មានព្រះដំណើរល្អ ទ្រង់ជ្រាបច្បាស់នូវត្រៃលោក ទ្រង់ប្រសើរដោយសីលាទិគុណ ឥតមានបុគ្គលណាស្មើ ទ្រង់ទូន្មាននូវបុរសដែលគួរទូន្មាន ទ្រង់ជាសាស្តានៃទេវតានិងមនុស្សទាំងឡាយ ទ្រង់ជ្រាបច្បាស់នូវចតុរារិយ

សច្ច ទ្រង់មានដំណើរទៅកាន់ត្រៃភពខ្ទាក់ចោលហើយ ដូចជាតថាគត ដែលឆ្ងាយចាកកិលេស ត្រាស់ដឹងញ្ញេយ្យធម៌ទាំងពួងដោយប្រពៃចំពោះខ្លួនឯង បរិបូរណ៍ដោយវិជ្ជានិងចរណៈ មានដំណើរល្អ ជ្រាបច្បាស់នូវត្រៃលោក ប្រសើរដោយសីលាទិគុណ ឥតមានបុគ្គលណាស្មើ ទូន្មាននូវបុរសដែលគួរទូន្មាន ជាសាស្តានៃទេវតានិងមនុស្សទាំងឡាយ ជ្រាបច្បាស់នូវចតុរារិយសច្ច មានដំណើរទៅកាន់ត្រៃភព ខ្ទាក់ចោលហើយ ដែលកើតឡើងក្នុងលោកក្នុងកាលឥឡូវនេះដែរ ។ ព្រះមេត្តេយ្យៈមានព្រះភាគព្រះអង្គនោះ ទ្រង់បានត្រាស់ដឹង បានធ្វើអោយជាក់ច្បាស់នូវព្រះនិព្វានចំពោះព្រះអង្គ ហើយញុំាំងលោកនេះ ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ញុំាំងពពួកសត្វព្រមទាំងសមណៈនិងព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេពនិងមនុស្សដ៏សេសអោយត្រាស់ដឹងផង ដូចតថាគតដែលបានត្រាស់ដឹង ហើយធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វានចំពោះខ្លួនឯង ហើយញុំាំលោកនេះ ហើយញុំាំងលោកនេះ ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ញុំាំងពពួកសត្វព្រមទាំងសមណៈនិងព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេពនិងមនុស្សដ៏សេសអោយត្រាស់ដឹងផង ក្នុងកាលឥឡូវនេះដែរ ។ ព្រះមេត្តេយ្យមានព្រះភាគអង្គនោះ នឹងទ្រង់សំដែងធម៌ពីរោះបទដើម ពីរោះបទកណ្តាល ពីរោះបទចុង ទាំងទ្រង់ប្រកាសព្រហ្មចរិយធម៌ ព្រមទាំងអត្ថនិងព្យញ្ជនៈ ដ៏ពេញបរិបូណ៌ បរិសុទ្ធទាំងអស់ ដូចតថាគតដែលសំដែងធម៌ ពីរោះបទចុងទាំងទ្រង់ប្រកាសព្រហ្មចរិយធម៌ ព្រមទាំងអត្ថ និងព្យញ្ជនៈ ដ៏ពេញបរិបូណ៌ បរិសុទ្ធទាំងអស់ក្នុងកាលឥឡូវនេះដែរ ។ ព្រះមេត្តេយ្យមានព្រះភាគអង្គនោះ នឹងគ្រប់គ្រងនូវភិក្ខុសង្ឃច្រើនពាន់ ដូចតថាគតដែលគ្រប់គ្រងនូវភិក្ខុសង្ឃច្រើនរយក្នុងកាលឥឡូវនេះដែរ ។

ម្នាលភិក្ខុទាំងឡាយ ក្នុងលំដាប់នោះឯង ព្រះបាទសង្ខៈទ្រង់ត្រាស់បង្គាប់អោយលើកប្រាសាទដែលព្រះបាទមហាបនាទៈអោយកសាង ហើយទ្រង់ប្រថាប់នៅក្នុងប្រាសាទនោះ ទ្រង់លះបង់ប្រាសាទនោះអោយជាទានដល់ពួកសមណៈព្រាហ្មណ៍ កបណៈ (មនុស្សកំព្រា) អទ្ធិក (អ្នកដំណើរ) វណិព្វកៈ (អ្នកនិយាយសរសើរហើយសូម) និង ពួកស្មូមយាចក រួចទ្រង់ដាក់

ព្រះកេសា និងព្រះមស្សុ ទ្រង់ស្លៀកដណ្តប់កាសាវព័ស្ត្រ ចេញចាក រាជាគារស្ថានចូលទៅកាន់ផ្នួសក្នុងសំណាក់នៃព្រះមេត្តេយ្យៈមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ។

កាលព្រះបាទសង្ខៈនោះ ទ្រង់ព្រះផ្នួសយ៉ាងនេះហើយ ទ្រង់គេចចេញទៅតែមួយព្រះអង្គឯង ឥតមានសេចក្តីប្រមាទឡើយ មានសេចក្តីព្យាយាមជាគ្រឿងដុតនូវកិលេស មានព្រះហឫទ័យបែរឆ្ពោះទៅរកព្រះនិព្វាន ពួកកុលបុត្រដែលចេញចាកផ្ទះ ទៅបួសក្នុងភាពជាបុគ្គលមិនមានផ្ទះដោយប្រពៃ ដើម្បីប្រយោជន៏ដល់អនុត្តរធម៌ណា ពុំយូរប៉ុន្មានក៏ព្រះសង្ខត្ថេរបានត្រាស់ដឹង បានធ្វើអោយជាក់ច្បាស់នូវអនុត្តរធម៌នោះ ដែលជាទីបំផុតនៃព្រហ្មចារ្យ ដោយខ្លួនឯងក្នុងបច្ចុប្បន្ននេះក៏សំរាកសម្រាន្តនៅ ដោយឥរិយាបទទាំងបួន ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរមានខ្លួនជាទីពឹង មានខ្លួនជាទីពំនាក់ កុំមានរបស់ដទៃជាទីពឹងពំនាក់ឡើយ ចូរមានធម៌ជាទីពឹង មានធម៌ជាទីពំនាក់ កុំមានរបស់ដទៃជាទីពឹងពំនាក់ឡើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានខ្លួនជាទីពឹង មានខ្លួនជាទីពំនាក់ មិនមានរបស់ដទៃជាទីពឹងពំនាក់ មានធម៌ជាទីពឹង មានធម៌ជាទីពំនាក់ មិនមានរបស់ដទៃជាទីពឹងជាទីពំនាក់ តើដូចម្តេច ? ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណានូវកាយក្នុងកាយជាប្រក្រតី មានព្យាយាមជាគ្រឿងដុតកំដៅនូវកិលេស មានប្រាជ្ញាដឹងសព្វ មានស្មារតី កំចាត់បង់នូវអភិជ្ឈា និង ទោមនស្ស ក្នុងលោកបាន ពិចារណានូវវេទនា ក្នុងវេទនាទាំងឡាយជាប្រក្រតី មានព្យាយាមជាគ្រឿងដុតនូវកិលេស មានប្រាជ្ញាដឹងសព្វ មានស្មារតីកំចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកបាន ពិចារណានូវចិត្ត ក្នុងចិត្តជាប្រក្រតី មានព្យាយាមជាគ្រឿងដុតនូវកិលេស មានប្រាជ្ញាដឹងសព្វ មានស្មារតីកំចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកបាន ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះហៅថា ភិក្ខុមានខ្លួនជាទីពឹង មានខ្លួនជាទីពំនាក់ មិនមានរបស់ដទៃជាទីពឹងពំនាក់ មានធម៌ជាទីពឹង មានធម៌ជាទីពំនាក់ មិនមានរបស់ដទៃជាទីពឹងពំនាក់ឡើយ ។

ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរប្រព្រឹត្ត ក្នុងគោចរជាវិស័យ ដែលមានមកអំពីបិតានៃខ្លួន ហើយនឹងចំរើនអាយុផង ចំរើនពណ៌សម្បុរផង ចំរើនសេចក្តីសុខផង ចំរើនភោគៈផង ចម្រើន

កំលាំងផង ។ ម្នាលភិក្ខុទាំងឡាយ ចុះអ្វីជាហេតុអោយចំរើនអាយុរបស់ភិក្ខុ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចំរើនឥទ្ធិបាទប្រកបដោយឆន្ទសមាធិ និងបធានសង្ខារ ចំរើនឥទ្ធិបាទប្រកបដោយវិរិយសមាធិនិងបធានសង្ខារ ចំរើនឥទ្ធិបាទប្រកបដោយចិត្តសមាធិ និងបធានសង្ខារ ចំរើនឥទ្ធិបាទប្រកបដោយវិមំសាសមាធិនិងបធានសង្ខារ ភិក្ខុនោះ បើមានបំណងនឹងរស់នៅ គប្បីឋិតនៅអស់ ១ អាយុកប្ប ឬ ១ អាយុកប្បច្ឆាយ ព្រោះហេតុដែលបានចំរើន បានធ្វើឱ្យច្រើននូវឥទ្ធិបាទទាំង៤ នេះ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងជាហេតុអោយចំរើនអាយុរបស់ភិក្ខុ ។ ម្នាលភិក្ខុទាំងឡាយចុះអ្វីជាហេតុអោយចំរើនពណ៌សម្បុររបស់ភិក្ខុ? ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីល សង្រួមក្នុងបាតិមោក្ខសំវរៈ បរិបូណ៌ដោយអាចារៈនិងគោចរ ជាអ្នកឃើញភ័យក្នុងទោស សូម្បីបន្តិចបន្តួច សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយនេះឯងជាហេតុអោយចំរើនសម្បុររបស់ភិក្ខុ ។ ម្នាលភិក្ខុទាំងឡាយ ចុះអ្វីជាហេតុអោយចំរើនសេចក្តីសុខរបស់ភិក្ខុ? ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ចូលបឋមជ្ឈាន ដែលប្រកបដោយ វិតក្កៈ វិចារៈ មានបីតិ និង សុខៈដែលកើតអំពីសេចក្តីស្ងប់ស្ងាត់ជាអារម្មណ៍ ភិក្ខុនោះ លុះរម្ងាប់វិតក្កវិចារៈរួចហើយ ក៏ចូលទុតិយជ្ឈាន ។ ចូលតតិយជ្ឈាន ។ ចូលចតុត្ថជ្ឈាន ។ ម្នាលភិក្ខុទាំងឡាយ នេះឯងជាហេតុអោយចំរើនសេចក្តីសុខរបស់ភិក្ខុ ។ ម្នាលភិក្ខុទាំងឡាយ ចុះអ្វីជាហេតុអោយចំរើនភោគៈរបស់ភិក្ខុ? ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ មានចិត្តប្រកបដោយមេត្តា ផ្សាយទៅកាន់ទិស១ ទិស២ ក៏ដូចគ្នា ទិស៣ ក៏ដូចគ្នា ទិស៤ក៏ដូចគ្នា តាមទំនងនេះ សូម្បីទិសខាងលើ ទិសខាងក្រោម ទិសទទឹង ក៏មានចិត្តប្រកបដោយមេត្តាដ៏ធំទូលាយរកប្រមាណមិនបាន មានចិត្តឥតមានចងពៀរ ឥតមានព្យាបាទផ្សាយទៅកាន់សត្វលោកទាំងអស់ក្នុងទិសទាំងពួង ។ មានចិត្តប្រកបដោយករុណា ។ មានចិត្តប្រកបដោយមុទិតា ។ មានចិត្តប្រកបដោយឧបេក្ខា ផ្សាយទៅកាន់ទិស១ ទិស២ ក៏ដូចគ្នា ទិស៣ ក៏ដូចគ្នា ទិស៤ក៏ដូចគ្នា តាមទំនងនេះ សូម្បី ទិសខាងលើ ទិសខាងក្រោម ទិសទទឹង ក៏មានចិត្តប្រកបដោយឧបេក្ខាដ៏ធំទូលាយរក

ប្រមាណមិនបាន មានចិត្តឥតមានចងពៀរ ឥតមានព្យាបាទផ្សាយទៅកាន់សត្វលោកទាំងអស់ ព្រោះហេតុប្រៀបផ្ទឹមខ្លួនអោយស្មើនឹងសត្វទាំងអស់ក្នុងទិសទាំងពួង ។ ម្នាលភិក្ខុទាំងឡាយ នេះឯងជាហេតុអោយចំរើនភោគៈរបស់ភិក្ខុ ។ ម្នាលភិក្ខុទាំងឡាយ ចុះអ្វីជាហេតុអោយចំរើនកំលាំងរបស់ភិក្ខុ ? ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានត្រាស់ដឹង បានធ្វើអោយជាក់ច្បាស់ដោយខ្លួនឯង នូវចេតោវិមុត្តិ និង បញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយក្នុងបច្ចុប្បន្ននេះ ហើយសម្រាកសម្រាន្ត ដោយឥរិយាបទទាំង៤ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងជាហេតុអោយចំរើនកំលាំងរបស់ភិក្ខុ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពិចារណាមើល មិនឃើញកំលាំងដទៃ សូម្បីតែកំលាំង១ ដែលបុគ្គលគ្របសង្កត់បានដោយកម្រអោយដូចជាកំលាំងនៃមារនេះឡើយ ម្នាលភិក្ខុទាំងឡាយ បុណ្យនេះតែងចំរើនឡើងយ៉ាងនេះ ព្រោះហេតុសមាទាននូវកុសលធម៌ទាំងឡាយ ។ លុះព្រះមានព្រះភាគទ្រង់សំដែងនូវព្រះសូត្រនេះចប់ហើយ ភិក្ខុទាំងនោះ ក៏មានចិត្តត្រេកអររីករាយចំពោះភាសិតរបស់ព្រះមានព្រះភាគ ។

## ចប់ចក្កវត្តិសូត្រ

ត្រឡប់ក្រោយ

ដកស្រង់ចេញពីសុត្តន្តបិដក ទីឃនិកាយ បញ្ចមវគ្គ លេខ ១៨

**ដោយភិក្ខុ វណ្ណគុត្តោ ស្វាត សាលឿម**